**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរការគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យ និងវិក្រឹតការខេត្តចំនួន១៥ និងសាលាអនុវត្តន៍ ឱ្យមកស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងអប់រំ យុវជន និងកីឡា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ .-**

ត្រូវបានផ្ទេរការគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្តចំនួន១៥ និងសាលាអនុវត្តន៍ ឱ្យមកស្ថិតក្រោម

ការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអភិវឌ្ឍធនធានគ្រូបង្រៀន គុណភាពបណ្តុះបណ្តាល និងវិក្រឹតការបុគ្គលិកអប់រំ ស្របតាមគោលនយោបាយកំណែទម្រង់គ្រូបង្រៀន និងកំណែទម្រង់វិស័យអប់រំ។

**មាត្រា២ .-**

មជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្រៃសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្តចំនួន១៥ និងសាលាអនុវត្តន៍ ដែលត្រូវបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា មានឈ្មោះនិងទីតាំងដូចខាងក្រោម៖

**ក. មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ**

១.មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម មានទីតាំងនៅក្រុងកំពង់ចាម ខេត្តកំពង់ចាម

២.មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ មានទីតាំងនៅក្រុងដូនកែវ ខេត្តតាកែវ

៣.មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង និងអនុវិទ្យាល័យអនុវត្តន៍ មានទីតាំងនៅក្រុងព្រៃវែង ខេត្តព្រៃវែង

៤.មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្តាល និងអនុវិទ្យាល័យ ហ៊ុន សែន អនុវត្តន៍ មានទីតាំងនៅក្រុងតាខ្មៅ ខេត្តកណ្តាល

៥.មជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្រៃសានខេត្តស្ទឹងត្រែង និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

**ខ. សាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងសាលាអនុវត្តន៍ទាំង១៥**

១.សាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពង់ចាម និងសាលាបឋមសិក្សាអនុវត្តន៍ ហ៊ុន សែន មានទីតាំងនៅក្រុងកំពង់ចាម ខេត្តកំពង់ចាម

២.សាលាគរុកោសល្យនិងវិក្រឹតការ ហ៊ុន សែន ខេត្តព្រៃវែង និងសាលាបឋមសិក្សាអនុវត្តន៍ ហ៊ុន សែន ព្រៃវែង មានទីតាំងនៅក្រុងព្រៃវែង ខេត្តព្រៃវែង

៣.សាលាគរុកោសល្យនិងវិក្រឹតការខេត្តតាកែវ និងសាលាបឋមសិក្សាអនុវត្តន៍ ហ៊ុន សែន តាកែវ មានទីតាំងនៅក្រុងដូនកែវ ខេត្តតាកែវ

៤.សាលាគរុកោសល្យនិងវិក្រឹតការខេត្តកណ្តាល និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងតាខ្មៅ ខេត្តកណ្តាល

៥.សាលាគរុកោសល្យនិងវិក្រឹតការ ហ៊ុន សែន ខេត្តកំពង់ធំ និងសាលាបឋមសិក្សា ហ៊ុន សែន អនុវត្តន៍ មានទីតាំងនៅក្រុងស្ទឹងសែន ខេត្តកំពង់ធំ

៦.សាលាគរុកោសល្យនិងវិក្រឹតការខេត្តសៀមរាប និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងសៀមរាប ខេត្តសៀមរាប

៧.សាលាគរុកោសល្យនិងវិក្រឹតការខេត្តក្រចេះ និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងក្រចេះ ខេត្តក្រចេះ

៨.សាលាគរុកោសល្យនិងវិក្រឹតការខេត្តស្វាយរៀង និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងស្វាយរៀង ខេត្តស្វាយរៀង

៩.សាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពត និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងកំពត ខេត្តកំពត

១០.សាលាគរុកោសល្យនិងវិក្រឹតការខេត្តព្រះសីហនុ និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

១១.សាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពង់ឆ្នាំង និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

១២.សាលាគរុកោសល្យនិងវិក្រឹតការខេត្តពោធិ៍សាត់ និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

១៣.សាលាគរុកោសល្យនិងវិក្រឹតការខេត្តបន្ទាយមានជ័យ និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ

១៤.សាលាគរុកោសល្យនិងវិក្រឹតការខេត្តព្រះវិហារ និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងព្រះវិហារ ខេត្តព្រះវិហារ

១៥.សាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពង់ស្ពឺ និងសាលាបឋមសិក្សាអនុវត្តន៍ មានទីតាំងនៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

**មាត្រា៣ ..**

បុគ្គលិកអប់រំ ថវិកា ចលនទ្រព្យ និងអចលនទ្រព្យគ្រប់ប្រភេទនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្តចំនួន១៥ និងសាលាអនុវត្តន៍ ត្រូវផ្ទេរមកឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំយន្តការការងារនិងគោលការណ៍សម្រាប់គ្រប់គ្រង ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ ..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបង្កើតគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀនដែលមានរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាជាប្រធាន ដើម្បីគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្ត សាលាអនុវត្តន៍ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនផ្សេងទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវគ្រោងកញ្ចប់ថវិកាដោយឡែកដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងសម្រាប់ដំណើរការការងាររបស់គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន។

**មាត្រា៥ ..**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការអនុវត្តសេចក្តីសម្រេចលេខ៤៨ ស.ស.រ. ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៨៣ស្តីពីការបណ្តុះបណ្តាលគ្រូកម្រិតសិក្សាទី១រយៈពេលវែងនៅតាមសាលាគរុកោសល្យនិងវិក្រឹតការខេត្តរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី សេចក្តីសម្រេចលេខ១៣៦ ស.ស.រ. ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៨៤ស្តីពីការបើកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង និងសេចក្តីសម្រេចលេខ១៣៧ ស.ស.រ. ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៨៤ស្តីពីការបង្កើតមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៦ សម្រាប់

បណ្តុះបណ្តាលនិងវិក្រឹតការគ្រូកម្រិតសិក្សាទី២របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មី មកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៥រោច ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ